**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
ក្រសួងមហាផ្ទៃ

**គោរពជូន**
**ឯកឧត្តម ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា គ២៧**

*ជាទីគោរព*

**កម្មវត្ថុ:** របាយការណ៍ ស្តីពី ពិធីប្រកាសជាផ្លូវការសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ ។

សេចក្តីដូចបានគោរពជម្រាបជូនក្នុងកម្មវត្ថុខាងលើ នាងខ្ញុំ សូមគោរពអនុញ្ញាតរាយការណ៍ ជូន **ឯកឧត្តម** មេត្តាជ្រាបថា ពិធីនេះបានប្រព្រឹត្តទៅ កាលពីថ្ងៃចន្ទ ២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង៩និង០០ នាទីព្រឹក តាមរយៈប្រព័ន្ធប្រជុំអនឡាញ (ZOOM) មានខ្លឹមសារដូចខាងក្រោម:

## I.សមាសភាពចូលរួម

**សមាសភាពគណៈអធិបតីរួមមាន:**

- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (ន.ក.ស.អ)
- លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានគណៈចលនាស្ត្រី
- លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ នៃព្រឹទ្ធសភា សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈចលនានារី និងជាអនុប្រធានគណៈកម្មាធិការ ន.ក.ស.អ ថ្នាក់កណ្តាល
- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការសាខាគ.២៧
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធាន ន.ក.ស.អ
- លោកជំទាវ **សាន្ត អរុណា** រដ្ឋលេខាក្រសួងកិច្ចការនារី សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធាន ន.ក.ស.អ

- លោកជំទាវ **ទូច សារ៉ុម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា សមាជិកាអចិន្ត្រៃយ៍ ន.ក.ស.អ
- ឯកឧត្តម **រាជ សុគន្ធ** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធានលេខាធិការដ្ឋាន គ.២៧
- លោកជំទាវ **តាន់ ផល្លី** សមាជិកាអចិន្ត្រៃយ៍ ន.ក.ស.អ
- លោកជំទាវ **មៀច សុធាវី** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ន.ក.ស.អ

**សមាជិកសមាជិកាចូលរួមអង្គពិធី រួមមាន:**

- លោកជំទាវអនុប្រធាន លោកជំទាវ លោកស្រី សមាជិកា នៃ សអ ក្រសួងមហាផ្ទៃ.ស.ក.ន. សរុបចំនួន ៤៩ រូប ស្រី ៤៧ រូប ។

**II.គោលបំណងនៃកម្មវិធី:**

ពិធីនេះមានគោលបំណងប្រកាសទទួលស្គាល់ជាផ្លូវការ សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃក្រសួងមហាផ្ទៃ ហៅកាត់ថា សាខាសមាគមនារី» ក្រសួងមហាផ្ទៃ ដែលមានសមាជិកភាពសរុបចំនួន «៣០រូប ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនារី នៃក្រសួងមហាផ្ទៃ អគ្គនាយិកា អគ្គនាយិការង អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន និងជាសមាជិកតាមបណ្តាអនុសាខានៃគណៈកម្មាធិការ គណបក្សប្រជាជន គ ២៧.និងមានលេខាធិការដ្ឋានមួយ ចែកចេញជាក្រុមការងាររដ្ឋបាល និងបូកសរុប មាន០៨រូប និងក្រុមការងារហិរញ្ញឹក មាន០៦រូបជាជំនួយ យោងតាមស្មារតី នៃ សេចក្តីសម្រេច លេខ១៦១នកសអ ២០//សសរ ដែលចុះហត្ថលេខាដោយ លោកជំទាវ ប្រធានគណៈកម្មាធិការកណ្តាល កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២០ ។

**III. ដំណើរការកម្មវិធី**

**លោកជំទាវ ជូ ប៊ុនអេង** ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងមហាផ្ទៃ បានថ្លែងនូវមតិស្វាគមន៍ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនារី ក្រសួងមហាផ្ទៃ គោរពជូនគណៈអធិបតី និងអង្គពិធី ដោយបានរំលេចកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចរបស់មន្ត្រីនារីក្រសួងមហាផ្ទៃ តាមតួនាទីកំណត់ក្រោមការដឹកនាំរបស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានចង្អុលណែនាំ និងដាក់ចេញនូវវិធានការ និងបទបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់មន្ត្រីក្រោមឱវាទក្នុងការសម្របសម្រួលការងារ រវាងអង្គភាពក្នុងស្ថាប័ន នៅថ្នាក់ជាតិ ជាតិក្រោមថ្នាក់រដ្ឋបាលនិង និងជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជម្រុញអនុវត្តគោលការណ៍ និងវិធានការនានា ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញឲ្យមានប្រសិទ្ធភាព ។ ក្នុងនោះ ដៃម្ខាងត្រូវរក្សាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពប្រជាពលរដ្ឋតាមភូមិ ឃុំ សង្កាត់ឲ្យមានប្រសិទ្ធិភាព ក៏ដូចជានៅតាម បណ្តាច្រកទ្វារព្រំដែន ទាំងច្រកទ្វារអន្តរជាតិ ទាំងច្រកទ្វារទ្វេភាគី ការធានាឲ្យបាននូវរបៀបរៀបរយ និងសុវត្ថិភាព សុខភាព ជាពិសេសការបង្ការទប់ស្កាត់ការឆ្លង និងចម្លងវីរុស កូវីដ ១៩ ក្នុងចំណោមជនទេសន្តប្រវេសន៍ដែលវិលត្រឡប់ពីបរទេសទៅសហគមន៍ ។ ចំនួនប្រជាជនកម្ពុជាវិលត្រឡប់ ជាពិសេសពីប្រទេសថៃ កើនឡើងរៀងរាល់ថ្ងៃ ដែលរហូតដល់បច្ចុប្បន្ន មានប្រមាណ

ជាង២៣ម៉ឺននាក់ ។ ដែម្ខាងទៀត ត្រូវជានាស្ថិរភាពជីវភាព បញ្ចៀសគ្រោះ ទុរ្ភិក្សអត់ឃ្លាន ដែលនាំបង្កឲ្យមានអសន្តិសុខ និងបទល្មើសផ្សេងៗ និងរក្សាសុវត្ថិភាពប្រជាពលរដ្ឋ រហូតរក្សាបាននូវ ស្ថេរភាពសង្គមនៅទូទាំងប្រទេស ។ ទន្ទឹមនឹងនោះ នារីក្នុងក្រសួងមហាផ្ទៃ ក៏បានចូលរួមសកម្មភាព បក្ស ដោយមានតួនាទី ជាសមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា៧រូប និងការងារចិញ្ចឹមចលនានៅមូលដ្ឋាន តាមបណ្តាខេត្ត ក្រុង ស្រុក សង្កាត់ ឃុំ ភូមិ ជាច្រើនផងដែរ ។

បន្ទាប់មក **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ នៃព្រឹទ្ធសភា និងជាអនុប្រធាន គណៈកម្មាធិការស អ ថ្នាក់កណ្តាល.ស.ក.ន.បានអានសេចក្តីសម្រេចលេខ១៦១នកសអ ២០//សសរ របស់គណៈកម្មាធិការសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ដែលចុះហត្ថលេខាដោយ លោកជំទាវ ប្រធានគណៈកម្មាធិការ កណ្តាល នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២០ ។

ដើម្បីបញ្ជាក់នូវស្មារតី គោរព អនុវត្តនូវគោលការណ៍ និងលក្ខន្តិកៈសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ **លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិនគរបាលជាតិ និងជាអនុប្រធានសមាគមនារីក្រសួងមហាផ្ទៃ បានឡើងអានសេចក្តីប្តេជ្ញាចិត្ត ក្នុងនាមជាតំណាងសមាជិកាគណៈកម្មាធិការសាខាសមាគមនារីក្រសួងមហាផ្ទៃ ដែលមាន ៨ចំនុច ដូចខាងក្រោមៈ

១-គោរព និងអនុវត្តខ្ជាប់ខ្ជួន នូវលក្ខន្តិកៈរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ដើម្បីឲ្យក្លាយជាកម្លាំងដែលសកម្ម និងមានគោលជំហរស្មោះត្រង់ជានិច្ចជាមួយគណបក្សប្រជាជនកម្ពុជា ។

២-ពង្រឹង និងពង្រីកសមាជិកភាពសមាគមនារី ក្នុងសាខាសមាគមនារី គ២៧ ឲ្យបានឆាប់រហ័សនឹងទៅជាកម្លាំងចលករមួយដ៏ធំធេង ដើម្បីចូលរួមធ្វើគ្រប់សកម្មភាពបម្រើបក្ស ដើម្បីជាផលប្រយោជន៍ដល់ប្រជាជន និងជាតិមាតុភូមិ ។

៣-ខិតខំយកចិត្តទុកដាក់ លើការពង្រឹងសតិអារម្មណ៍នយោបាយ បង្កើនស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងសមាគមនារី ដោយពង្រីកទំនាក់ទំនងល្អ ជាមួយកម្លាំងដទៃទៀតដែលគាំទ្របក្សប្រជាជនកម្ពុជា ។

៤-គោរពការចាត់តាំង និងសេចក្តីណែនាំ របស់គណបក្សប្រជាជនកម្ពុជា គណៈចលនានារី សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ។

៥-ប្តេជ្ញាចូលរួមក្នុងសកម្មភាពសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្នុងបុព្វហេតុ ចូលរួមចំណែកឆ្លើយតបទៅនឹង សេចក្តីត្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយប្រកាន់យកការផ្សារភ្ជាប់ការងារស្នូល ទៅនឹងការងារសង្គម ការងារមនុស្សធម៌ និងការលើកកម្ពស់ស្ថានភាពជីវភាពប្រជាពលរដ្ឋឲ្យបានប្រសើរឡើង ។

៦-ប្តេជ្ញាបំពេញភារកិច្ច ដែលកំណត់ដោយក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល តាមតួនាទីរៀងៗខ្លួន ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដែលនាំមកនូវភាពជោគជ័យ ក្នុងការបម្រើសេវាសាធារណៈចាំបាច់ជូនប្រជាពលរដ្ឋ រក្សាបានការការពារសន្តិសុខ សុវត្ថិភាព និងរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ ជូនដល់សង្គមជាតិទាំងមូល ។

៧-ចូលរួមសកម្មភាពមូលដ្ឋាន និងចលនាគណបក្ស ជាពិសេស ក្នុងដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០២២ខាងមុខ និងការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០២៣ ដោយការជម្រុញដល់សមាជិក និងគ្រួសារបក្ស នីមួយៗ បានបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ម្នាក់មួយសន្លឹក ដោយចាប់ផ្តើមពីសមាជិកសមាគមនារី គ២៧ ខ្លួនឯងនេះទៅ ។

៨-ក្នុងនាមជាភរិយា ជាម្តាយ ជាមីង ជាបងស្រី ប្តេជ្ញានឹងខិតខំយកចិត្តទុកដាក់ដាស់តឿន អប់រំ ដល់ក្រុមគ្រួសារ ក៏ដូចជាដល់សង្គម យុវជន យុវនារី តាមរយៈវេទិកាសាធារណៈនានា ដើម្បីឲ្យពួកគេបានយល់ដឹងអំពីសីលធម៌ ដ៏ល្អផូរផង់របស់នារីខ្មែរ ជៀសផុតពីគ្រឿងញៀន គោរពច្បាប់ចរាចរ ថែរក្សាប្រពៃណី វប្បធម៌ជាតិឲ្យបាន គង់វង្ស និងចូលរួមគោរពឲ្យបានម៉ឺងម៉ាត់នូវគោលការណ៍រដ្ឋាភិបាល ៣កុំ និង៣ការពារ ធ្វើយ៉ាងណាទប់ស្កាត់ បង្រ្កាប និងលុបបំបាត់ការចម្លងនៃវីរុសកូវីដ១៩ ពីកម្ពុជាក្នុងពេលដ៏ខ្លីខាងមុខនេះ ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក៏បាននាំនូវការផ្តាំផ្ញើ សួរសុខទុក្ខ និងការនឹករលឹកពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍** ជូនដល់អង្គពិធីទាំងមូល។ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ក៏បានថ្លែងនូវការកោតសរសើរចំពោះ លោកជំទាវ ជូ ប៊ុនអេង និងថ្នាក់ដឹកនាំរបស់ស្ត្រីគ្រប់លំដាប់ថ្នាក់ នៃក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងស្មារតីទទួលខុសត្រូវក្នុងការបំពេញភារកិច្ចក្នុងរយៈពេលកន្លងមក រហូតទទួលបានជោគជ័យគួរជាទីមោទនៈ ដែលបានជំរុញមន្ត្រីរាជការជានារីបានរួមចំណែកកាន់តែសកម្មថែមទៀតក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយចាត់ទុក "ស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម" ។ **លោកជំទាវ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានអនុញ្ញាតបង្កើតសមាគមនារីក្រសួងមហាផ្ទៃ ដើម្បីជាសេនាធិការជូនសាខាគណបក្សប្រជាជនកម្ពុជា គ២៧ ក្នុងការបំពេញភារកិច្ចចំពោះបុព្វហេតុនារី ។ ទោះបីជាក្នុងខណៈពេលដែលគណៈកម្មាធិការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍របស់ក្រសួងពុំទាន់បានបង្កើត និងប្រកាសជាផ្លូវការយ៉ាងណាក៏ដោយ ក៏នារីក្រសួងមហាផ្ទៃបានបំពេញការងារយ៉ាងសកម្ម គួរឲ្យកត់សម្គាល់ និងទទួលបានលទ្ធផលល្អប្រសើរ ។ ទន្ទឹមនឹងនេះផងដែរ លោកជំទាវកិត្តិសង្គហបណ្ឌិត ក៏បានផ្តល់អនុសាសន៍មួយចំនួន ជូនដល់សមាជិកា គណៈកម្មាធិការសមាគមនារី នៃក្រសួងមហាផ្ទៃ ដែលត្រូវបានប្រកាសជាផ្លូវការនាថ្ងៃនេះ ដូចខាងក្រោម៖

១-បំផុសចលនាអប់រំ ផ្សព្វផ្សាយឲ្យបានទូលំទូលាយជាប្រចាំ តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយនូវគោលនយោបាយ ខ្លឹមសារ សេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល ។ ជាពិសេស ចូលរួមអនុវត្តឲ្យបាននូវគោលនយោបាយភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព ក្នុងនោះត្រូវផ្តោតសំខាន់លើការផ្តល់សេវាសាធារណៈឲ្យបានឆាប់

រហ័សប្រកបដោយប្រសិទ្ធិភាព មិនត្រូវបង្កការលំបាក និងមានការរំខានដល់ការផ្តល់សេវាគាំពារសង្គមជូនប្រជាពលរដ្ឋ ដែលភាគច្រើនគឺជាស្ត្រីដែលបានទទួលអត្ថប្រយោជន៍នេះ ។

២-ពង្រឹងរបៀបរបបធ្វើការងារ អនុវត្តនូវតួនាទីភារកិច្ច ដោយត្រូវបែងចែកភារកិច្ច និងការទទួលខុសត្រូវ ដល់ថ្នាក់ដឹកនាំគណៈកម្មាធិការសាខាសមាគមនារីក្រសួងមហាផ្ទៃ ដែលទើបបានតែងតាំងជាផ្លូវការនាពេលនេះ ត្រូវរៀបចំ ឲ្យមានរបបប្រជុំ និងរបៀបរបបដោះស្រាយបញ្ហា ដើម្បីការពារផលប្រយោជន៍ដល់ស្ត្រី នៅក្រសួងមហាផ្ទៃក៏ដូចជាផលប្រយោជន៍ស្ត្រីនៅថ្នាក់ក្រោមជាតិផងដែរ ។

៣-អនុវត្តឲ្យបានជោគជ័យ នូវផែនការសកម្មភាពសម្រាប់រយៈពេល៤ឆ្នាំ (២០២០-២០២៣) របស់សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ដើម្បីតម្រង់ទិសទៅជណ្តើមជោគជ័យក្នុងការបោះឆ្នោត ២០២២-២០២៣ ។

៤-ជំរុញឱ្យស្ត្រីដែលមានតួនាទី ត្រូវខិតខំបំពេញតួនាទី ភារកិច្ចតាមជំនាញនីមួយៗ ក្នុងការកសាងនិងបង្កើនសមត្ថភាព ជឿជាក់លើខ្លួនឯង ដើម្បីឱ្យស្ត្រីទទួលបានឋានៈតួនាទី និងចូលរួមធ្វើសេចក្តីសម្រេចឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

៥-ត្រូវបន្តផ្សព្វផ្សាយលក្ខន្តិកៈរបស់សមាគមនារី ពង្រឹងសមាជិកចាស់ និងពង្រីកសមាជិកថ្មី និង បង្កើតអនុសាខាសមាគមនារីរបស់ក្រសួងមហាផ្ទៃឲ្យសមស្រប តាមបច្ចុប្បន្នភាពរបស់ក្រសួងមហាផ្ទៃ ។

៦-ពង្រឹងនិងថែរក្សានូវស្មារតីសាមគ្គីភាព ឯកភាពគ្នាខាងទស្សនៈ គោលជំហរ នយោបាយសតិអារម្មណ៍ ចាត់តាំងឲ្យកាន់តែរឹងមាំ។ ជាពិសេសត្រូវចេះសហការ និងទទួលយកនូវការដឹកនាំនិងការផ្តល់យោបល់ជាមួយថ្នាក់ដឹកនាំក្រសួង។

៧-ត្រូវធ្វើរបាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំរបស់ក្រសួង និងសមាគមនារីថ្នាក់កណ្តាល ។

ពិធីប្រកាស ដែលប្រព្រឹត្តទៅតាមរយៈប្រព័ន្ធ ZOOM ជារបៀបធ្វើការតាមគន្លងថ្មីនេះ បានដំណើរការយ៉ាងរលូន និងបញ្ចៀសបាននូវហានិភ័យ ដោយកូវីដ-១៩ និងបានបញ្ចប់នាថ្ងៃខែឆ្នាំដដែល ប្រកបបរិយាកាសរីករាយ និងមានអត្ថន័យ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តម ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា គ២៧** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ.ពុធ..៤..រោច..ខែទុតិយសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី.២៨..ខែ....កក្កដា...ឆ្នាំ២០២១
**ប្រធានសមាគមនារីក្រសួងមហាផ្ទៃ**

ឌុំ-ប៊ុនអេង